# សកម្មភាព
# ចូរមកតាមខ្ញុំ

*សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ឬការសិក្សាព្រះគម្ពីរ—ឬគ្រាន់តែសម្រាប់ភាពរីករាយ !*



ថ្ងៃទី ២៨ ខែ តុលា–ថ្ងៃទី ៣ ខែ វិច្ឆិកា

## ចូរស្រឡាញ់គ្នាទៅវិញទៅមក

សម្រាប់ មរមន ១–៦

មរមនស្រឡាញ់ពួកសាសន៍នីហ្វៃ ( សូមមើល មរមន ៣:១២ ) ។ ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទបានសុំឲ្យយើងស្រឡាញ់អ្នកដទៃផងដែរ ។ សូមឈរក្នុងរង្វង់ ហើយបិទភ្នែករបស់ប្អូនៗ ។ ចូររាប់ដល់ ៣ រួចមកបើកភ្នែក ហើយមើលទៅនរណាម្នាក់ ។ បើប្អូនៗកំពុងសម្លឹងភ្នែកគ្នាទៅវិញទៅមកជាមួយពួកគេ សូមនិយាយអ្វីដែលប្អូនៗចូលចិត្តអំពីគ្នាទៅវិញទៅមក ហើយដើរចេញពីរង្វង់វិញ ។ បន្តធ្វើបែបនេះរហូតដល់មានតែមនុស្សម្នាក់នៅសល់ ! ក្រោយមកទាំងអស់គ្នានិយាយអ្វីដែលពួកគេចូលចិត្តអំពីបុគ្គលនោះ ។

**សម្រាប់កុមារតូចៗ ៖** សូមតាមប្រមាញ់ « សេចក្តីស្រឡាញ់ » ទាំងនៅក្នុងផ្ទះរបស់ប្អូនៗ ឬនៅខាងក្រៅ ។ សូមអញ្ជើញកូនតូចៗរបស់អ្នកឲ្យស្វែងរកអ្វីដែលរំឭកពួកគេអំពីមនុស្សដែលពួកគេស្រឡាញ់ ។



ថ្ងៃទី ៤–១០ ខែ វិច្ឆិកា

## រូបគំនូរពេញដោយអព្ភូតហេតុ

សម្រាប់ មរមន ៧–៩

នៅពេលយើងធ្វើតាមព្រះយេស៊ូវគ្រីស្ទ ព្រះវរបិតាសួគ៌អាចប្រទានពរដល់យើងនូវអព្ភូតហេតុ ។ សូមអាន មរមន ៨:២៤ ហើយគូរអំពីអព្ភូតហេតុមួយដែលបានរៀបរាប់នៅក្នុងខគម្ពីរ ។ ពេលដែលប្អូនៗគូរ សូមនិយាយអំពីអព្ភូតហេតុដែលព្រះវរបិតាសួគ៌បានធ្វើសម្រាប់គ្រួសាររបស់ប្អូន ។

**សម្រាប់កុមារតូចៗ ៖** ចូរពន្យល់ដល់កូនតូចៗរបស់អ្នកថាអ្វីទៅជាអព្ភូតហេតុ ។ បន្ទាប់មកច្រៀង ឬស្តាប់បទ « អព្ភូតហេតុ » ( *Liahona* ខែ មិថុនា ឆ្នាំ ២០១៨ ទំព័រ ៧២-៧៣ ) ។



ថ្ងៃទី១១–១៧ ខែវិច្ឆិកា

## ការគូរគំនូរថ្ម

សម្រាប់ អេធើរ ១–៥

បងប្រុសរបស់យ៉ារេឌបានទូលសុំឲ្យព្រះអម្ចាស់ពាល់ក្រួស ដើម្បីឲ្យទូករបស់លោកអាចមានពន្លឺ ( សូមមើល អេធើរ ៣ ) ។ សូមប្រមូលក្រួសពីខាងក្រៅ ឬកាត់រង្វង់ចេញពីបំណែកក្រដាស ។ នៅលើក្រួស ឬក្រដាសរបស់ប្អូនៗ សូមសរសេរ គូរ ឬផាត់ពណ៌របស់ដែលប្អូនអាចធ្វើដើម្បីនាំឲ្យមានពន្លឺ និងសេចក្ដីស្រឡាញ់ដល់អ្នកដទៃ ។

**សម្រាប់កុមារតូចៗ ៖** សូមអាន អេធើរ ៣:១៥ ឲ្យកូនតូចៗរបស់អ្នកស្តាប់ ហើយប្រាប់ពួកគេថា យើងត្រូវបានបង្កើតឡើងតាមរូបរាងរបស់ព្រះ ។ បន្ទាប់មក សូមធ្វើអាហារសម្រន់ដែលមានសុខភាពល្អ ឬដើរជាមួយគ្នាដើម្បីថែរក្សារូបកាយដែលព្រះបានប្រទានឲ្យអ្នក ។





ថ្ងៃទី ១៨–២៤ ខែ វិច្ឆិកា

## ចម្រៀងថ្លែងអំណរគុណ

សម្រាប់ អេធើរ ៦–១១

នៅពេលពួកគេធ្វើដំណើរឆ្លងកាត់សមុទ្រ បងប្រុសរបស់យ៉ារេឌ និងក្រុមគ្រួសាររបស់លោកបានច្រៀងសរសើរតម្កើងដល់ព្រះអម្ចាស់ ដើម្បីថ្លែងអំណរគុណដល់ទ្រង់ដែលបានជួយពួកគេ ( សូមមើល អេធើរ ៦:៩ ) ។ ប្អូនៗក៏អាចច្រៀងដើម្បីថ្លែងអំណរគុណដល់ព្រះអម្ចាស់ផងដែរ ! សូមជ្រើសយកចម្រៀងដែលពេញចិត្តចេញពី *សៀវភៅចម្រៀងកុមារ* ឬ គេហទំព័រសាសនាចក្រ ហើយច្រៀងចម្រៀងនោះជាមួយគ្នា ។ តើប្អូនៗអាចបង្ហាញការថ្លែងអំណរគុណដល់ព្រះវរបិតាសួគ៌បានយ៉ាងដូចម្ដេច ?

**សម្រាប់កុមារតូចៗ ៖** ជាមួយនឹងកូនតូចៗរបស់អ្នក សូមធ្វើពុតថាអ្នកនៅក្នុងទូកដូចជាពួកសាសន៍យ៉ារេឌដែរ ។ សូមច្រៀងចម្រៀងកុមារដែលអ្នកចូលចិត្តខណៈរខ្លួនតាមចង្វាក់ភ្លេងទៅវិញទៅមក !

